# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តព្រះសីហនុ**

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តព្រះសីហនុ

**-សំណុំរឿងរដ្ឋប្បវេណី**

លេខ: ៨៦

ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩

**-សាលក្រមរដ្ឋប្បវេណី**

លេខ: ៨០/០៩ (ច)

ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៩

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ ដែលមានសមាសភាពដូចតទៅ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តព្រះសីហនុ

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តព្រះសីហនុ

-ដើមចោទឈ្មោះ [redacted] ថារ៉ូ ភេទស្រី កើតឆ្នាំ១៩៨៤ ជនជាតិខ្មែរ [redacted]។

អ្នកតំណាងដោយអាណត្តិលោកមេធាវី [redacted] និងលោកមេធាវី [redacted] មានការិយាល័យ [redacted]។

អ្នកតំណាងដោយអាណត្តិលោកមេធាវី [redacted]។

-ចុងចម្លើយឈ្មោះ [redacted] ណារីទ្ធ ភេទប្រុស កើតឆ្នាំ១៩៨១ ជនជាតិខ្មែរ [redacted]។

**<u>អង្គហេតុ និង ចំណុចវិវាទ</u>**

១.សាលក្រមទាមទារដោយដើមចោទ

ក.ឲ្យឈ្មោះ [redacted] ថារ៉ូ និងឈ្មោះ [redacted] ណារីទ្ធ លែងលះគ្នា។

ខ.សុំសិទ្ធិគ្រប់គ្រងថែរក្សាកូនឈ្មោះ [redacted] សុមុនី ភេទប្រុស កើតនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៨។

គ.សុំបែងចែកទ្រព្យរួមជាពីរចំណែកស្មើគ្នា៖

-ដី និងផ្ទះលំនៅឋាន មានទីតាំងស្ថិតនៅភូមិ១ សង្កាត់លេខ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ១៨០១០៤០៥-៣៨៩០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦។

-រថយន្តម៉ាកLEXUS RX300 ពណ៌ស ស្លាកលេខ ភ្នំពេញ 2Z-០៣២២។

ឃ.សុំទាមទារប្រាក់អាហារកិច្ចចំនួនUSD២០០ ក្នុងមួយខែ។



Scanned with CamScanner

ង.ប្រាក់ប្រដាបើក្តីជាបន្ទុករបស់ចុងចម្លើយ។

*២-ការអះអាងរបស់ភាគី:*

ក.ដើមចោទឈ្មោះ [redacted] ថារ៉ូ ថ្លែងការណ៍ថា៖ ខ្ញុំមិនអាចសះជាជាមួយឈ្មោះ [redacted] ណារីរ័ត្ន ទេ ហើយប្រកាន់ជំហរប្តឹងសុំលែងលះដដែល ដោយមូលហេតុពួកខ្ញុំរស់ជាមួយគ្នាមិនចុះសម្រុងជាមួយគ្នា។ ពួកខ្ញុំរៀបអាពាហ៍ពិពាហ៍នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅមន្ត្រីអនុក្រានុកូលរដ្ឋានសង្កាត់លេខ៣។ សព្វថ្ងៃពួកខ្ញុំរស់នៅបែកគ្នារយៈពេល០៣ខែមកហើយ។ អំឡុងពេលរស់នៅជាមួយគ្នាជាប្តីប្រពន្ធកន្លងមក នាងខ្ញុំមានកូនចំនួន០១នាក់ ឈ្មោះ [redacted] សុមុនី ភេទប្រុស កើតថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៨ សព្វថ្ងៃរស់នៅជាមួយខ្ញុំ ហើយឈ្មោះ [redacted] ណារីរ័ត្ន យកទៅលេងម្តងម្កាល។ កូននេះខ្ញុំសុំគ្រប់គ្រងចិញ្ចឹម ដោយទាមទារអាហារកិច្ចចិញ្ចឹមកូនក្នុងមួយខែ២០០$ គិតចាប់ពីថ្ងៃចេញសាលក្រម។ ទ្រព្យសម្បត្តិរួមមានដី និងផ្ទះលំនៅឋាន មានទីតាំងស្ថិតនៅភូមិ១ សង្កាត់លេខ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ១៨០១០៤០៥-៣៣៩០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦ និងរថយន្តម៉ាកLEXUS RX300 ពណ៌ស ស្លាកលេខ ភ្នំពេញ 2Z-០៣២២ ដោយដី និងផ្ទះ ខ្ញុំស្នើសុំលក់ ហើយខ្ញុំសុំបែងចែកជាពីរចំណែកស្មើគ្នា។ ចំណែករថយន្តម៉ាកLEXUS RX 300 ពណ៌ស ស្លាកលេខ ភ្នំពេញ 2Z-០៣២២ ចុងចម្លើយកំពុងជិះ ខ្ញុំស្នើសុំលក់ ហើយខ្ញុំសុំបែងចែកជាពីរចំណែកស្មើគ្នា។ បំណុលរួមមាន ប៉ុន្តែមិនចាំបាច់ឲ្យតុលាការពិនិត្យសម្រេចទេ ព្រោះពួកខ្ញុំសម្របសម្រួលគ្នានៅក្រៅតុលាការ។

ខ.ចុងចម្លើយឈ្មោះ [redacted] ណារីរ័ត្ន ថ្លែងការណ៍តបថា៖ ខ្ញុំសូមរក្សាសេចក្តីថ្លែងការណ៍ នៅក្នុងកំណត់ហេតុត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី៩៦ ខែមិថុនា ឆ្នាំ២០១៩ ដដែល។ ខ្ញុំឯកភាពយល់ព្រមលែងលះតាមការស្នើសុំរបស់ដើមចោទឈ្មោះ [redacted] ថារ៉ូ។ បានជាលែងលះ គឺដោយសារមូលហេតុគំនិតផ្សេងគ្នាជាច្រើន ធ្វើឲ្យរស់នៅមិនចុះសម្រុងនឹងគ្នា រហូតឈានដល់ការលែងលះគ្នា។ ពួកខ្ញុំរៀបអាពាហ៍ពិពាហ៍នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅមន្ត្រីអនុក្រានុកូលរដ្ឋានសង្កាត់លេខ៣។ សព្វថ្ងៃពួកខ្ញុំមានកូនចំនួន០១នាក់ ឈ្មោះ [redacted] សុមុនី ភេទប្រុស កើតថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៨ សព្វថ្ងៃរស់នៅជាមួយដើមចោទ កូននេះខ្ញុំសុំទាមទារចិញ្ចឹម មិនឯកភាពប្រគល់ឲ្យភាគីដើមចោទទេ ដោយហេតុថា ខ្ញុំជាអ្នកមើលថែរក្សា ឃឹស្កាត់ និងអប់រំរៀនសូត្រគាត់ទៅថ្ងៃអនាគត។ សព្វថ្ងៃខ្ញុំធ្វើការនៅសណ្ឋាគារ ខតយ៉ាតភ្នំពេញ ទទួលប្រាក់ខែក្នុងមួយខែ៣៣០០$ និងប្រាក់ផ្សេងៗទៀតចំនួន២០០$ និងអាចមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចិញ្ចឹមកូន។ ចំពោះកូន ប្រសិនបើតុលាការប្រគល់មកឲ្យខ្ញុំ ខ្ញុំមិនទាមទារអាហារកិច្ចចិញ្ចឹមកូនទេ។ ចំពោះទ្រព្យសម្បត្តិរួមមានដី និងផ្ទះលំនៅឋាន មានទីតាំងស្ថិតនៅភូមិ១ សង្កាត់លេខ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ១៨០១០៤០៥-៣៣៩០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦ និងរថយន្តម៉ាកLEXUS RX300 ពណ៌ស ស្លាកលេខ ភ្នំពេញ 2Z-០៣២២ ដែលដើមចោទស្នើសុំលក់បែងចែកចំណែកជាពីរស្មើគ្នា ខ្ញុំឯកភាពតាម។ បំណុលរួមមាន ប៉ុន្តែមិនចាំបាច់ឲ្យតុលាការពិនិត្យសម្រេចទេ ព្រោះពួកខ្ញុំសម្របសម្រួលគ្នានៅក្រៅតុលាការ។

៣.ដើមចោទឈ្មោះ [redacted] ថារ៉ូ ថ្លែងការណ៍ថា៖ ចំពោះកូន ប្រសិនបើរស់នៅជាមួយចុងចម្លើយ ចុងចម្លើយពុំមានពេលវេលាគ្រប់គ្រាន់ក្នុងការចិញ្ចឹមថែរក្សាបីបាច់ទេ ព្រោះគាត់រស់នៅភ្នំពេញម្នាក់ឯង ចំណែកឪពុកម្តាយក្មេកខ្ញុំរស់នៅខេត្តកំពង់ចាម បើឲ្យកូនទៅចុងចម្លើយ កូនត្រូវប្រគល់ឲ្យឪពុកម្តាយក្មេកខ្ញុំនៅខេត្តកំពង់ចាម ជាអ្នកមើលថែ ដែលធ្វើឲ្យកូនរស់នៅខ្វះភាពកក់ក្តៅពីឪពុកម្តាយ។ ចំណែកខ្ញុំរស់នៅជាមួយឪពុកម្តាយខ្ញុំ ព្រមទាំងប្អូនស្រីខ្ញុំ ហើយខ្ញុំមានលទ្ធភាពថែរក្សា ចិញ្ចឹមកូនបាន ខ្ញុំធ្វើការនៅសណ្ឋាគារសុខា ខេត្តព្រះសីហនុ ទទួលបានប្រាក់ខែ៩០០$ ក្នុងមួយខែ ដោយមិនគិតប្រាក់ផ្សេងៗទេ។ ម៉្យាងវិញទៀត កូននេះទើបតែអាយុ១ឆ្នាំ ២ខែ នៅតូចទាមទារការមើលថែរក្សាពីខ្ញុំដែលជាម្តាយ។

៤.អ្នកតំណាងដោយអាណត្តិឲ្យដើមចោទលោកមេធាវី [redacted] បានថ្លែងការណ៍រួមគ្នាថា៖ ខ្ញុំឯកភាពតាមការអះអាង និងការទាមទាររបស់កូនក្តីខ្ញុំបាទឈ្មោះ [redacted] ថារ៉ូ ដូចមាននៅ

ក្នុងពាក្យបណ្តឹងដាក់ជូនមកតុលាការ។ ក្រោយពីការអះអាងរបស់ដើមចោទ និងចុងចម្លើយ នៅក្នុងនីតិវិធីត្រៀមទាញហេតុផលនេះ គឺគ្រប់ចំណុចទាំងអស់ពួកគាត់បានឯកភាពគ្នា លើកលែងតែកូនឈ្មោះ [redacted] សុមុនី ភេទប្រុស កើតថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៨ មូលហេតុដែលកូនក្តីខ្ញុំទាមទារដោយសំអាងលើ ១/អាយុរបស់ឈ្មោះ [redacted] សុមុនី ទើបតែអាយុ១ឆ្នាំ ២ខែ ប៉ុណ្ណោះ គឺគាត់ស្ថិតនៅក្រោមការចិញ្ចឹមរបស់ម្តាយ ២/កូនក្តីខ្ញុំបាទមានការងារធ្វើត្រឹមត្រូវ ទទួលបានប្រាក់ខែរហូត៩០០$ ក្នុងមួយខែ ៣/ គាត់មានផ្ទះសំបែងច្បាស់លាស់រួមជាមួយឪពុកម្តាយបង្កើតរបស់គាត់ និងប្អូនស្រី ដែលអាចជួយមើលថែកូនរបស់គាត់បាននៅពេលដែលគាត់រវល់ការងារ និងមានភាពងាយស្រួលនៅពេលដែលកូនគាត់ចូលរៀនបាន។

## ៣- ការពន្យល់ត្រួសៗអំពីរឿងក្តី

### -អង្គហេតុដែលជាមូលហេតុនៃការទាមទារ

ដើមចោទឈ្មោះ [redacted] ថាវ៉ូ និងចុងចម្លើយឈ្មោះ [redacted] ណារីត្ន បានរស់នៅជាមួយគ្នាជាប្តីប្រពន្ធតាំងពីឆ្នាំ២០១៣ និងបានបង្កើតកូនប្រុសចំនួន ០១នាក់ ឈ្មោះ [redacted] សុមុនី ភេទប្រុស កើតនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៨។ ខ្លួន និងឈ្មោះ [redacted] ណារីត្ន បានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៣ ចាប់តាំងពីថ្ងៃដែលរស់នៅជាប្តីប្រពន្ធរហូតមកដល់បច្ចុប្បន្ន ខ្លួនបានខិតខំធ្វើការរកស៊ីចិញ្ចឹមគ្រួសាររហូតមក។ នៅក្នុងអំឡុង០២ឆ្នាំចុងក្រោយនេះ ឈ្មោះ [redacted] ណារីត្ន មិនបានបំពេញកាតព្វកិច្ចជាប្តីទេ ដោយគាត់មិនមើលថែ និងគ្រប់គ្រងគ្រួសារ។

## ៤- ចំណុចវិវាទ

-កូនឈ្មោះ [redacted] សុមុនី ភេទប្រុស កើតថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៨ ដើមចោទឈ្មោះ [redacted] ថាវ៉ូ ទាមទារគ្រប់គ្រងចិញ្ចឹម និងសុំអាហារកិច្ចចិញ្ចឹមកូនក្នុងមួយខែ២០០$ គិតចាប់ពីថ្ងៃចេញសាលក្រម។ រីឯចុងចម្លើយឈ្មោះ [redacted] ណារីត្ន ក៏បានស្នើសុំទាមទារគ្រប់គ្រងចិញ្ចឹមកូនដែរ តែមិនទាមទារអាហារកិច្ចចិញ្ចឹមកូនទេ។

## **<u>សំអាងហេតុ</u>**

១.ដើមចោទឈ្មោះ [redacted] ថាវ៉ូ និងចុងចម្លើយឈ្មោះ [redacted] ណារីត្ន ពិតជាបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាជាប្តីប្រពន្ធនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ នៅមន្ត្រីអត្រានុកូលដ្ឋានសង្កាត់លេខ៣ តាមលិខិតលេខៈ ៨៦ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៣។

២.គូភាគីអះអាងនៅដំណាក់កាលទាញហេតុផលដោយផ្ទាល់មាត់ថា ការរស់នៅជាមួយគ្នាមិនចុះសម្រុងនឹងគ្នា ហើយគូភាគីបានបែកលំនៅពីគ្នា ជាហេតុធ្វើឲ្យគូភាគីអស់មនោសញ្ចេតនាជាប្តីប្រពន្ធនឹងគ្នា ហើយគូភាគីបានឯកភាពលែងលះជាមួយគ្នាដោយស្ម័គ្រចិត្ត ហេតុនេះតុលាការសម្រេចសេចក្តីតាមការព្រមព្រៀងរបស់គូភាគី យោងតាមមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី។

៣.ការរស់នៅជាមួយគ្នាកន្លងមក គូភាគីមានកូន០១នាក់ ឈ្មោះ [redacted] សុមុនី ភេទប្រុស កើតនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៨ ដោយកូននេះ ដើមចោទឈ្មោះ [redacted] ថាវ៉ូ សុំសិទ្ធិជាអ្នកគ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សា និងសុំអាហារកិច្ចចិញ្ចឹមកូនក្នុងមួយខែចំនួន២០០$ គិតចាប់ពីថ្ងៃចេញសាលក្រម។ ចំណែកចុងចម្លើយឈ្មោះ [redacted] ណារីត្ន ក៏បានសុំសិទ្ធិជាអ្នកគ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សាកូន។ ចំណុចនេះ តុលាការយល់ឃើញថា គូភាគី សុទ្ធតែមានលទ្ធភាពចិញ្ចឹមកូនបានល្អដូចគ្នា។ ក៏ប៉ុន្តែ កូននេះនៅតូចបើឲ្យរស់នៅជាមួយដើមចោទដែលជាម្តាយ មានភាពកក់ក្តៅជាងឪពុក ដូច្នេះ គប្បីប្រគល់កូនឈ្មោះ [redacted] សុមុនី ឲ្យទៅដើមចោទឈ្មោះ [redacted] ថាវ៉ូ គ្រប់គ្រង ចិញ្ចឹមបីបាច់ថែរក្សា យោងតាមបញ្ញត្តិមាត្រា ១០៣៧ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី។

៤.ភាគីដែលពុំមានអំណាចមេបា មានសិទ្ធិទៅសួរសុខទុក្ខកូន។ រីឯភាគីដែលទទួលសិទ្ធិថែរក្សាកូន ត្រូវបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងដល់ភាគីម្ខាងទៀត។ តែតម្រូវឲ្យចុងចម្លើយឈ្មោះ [redacted] ណារីត្ន ផ្តល់អាហារកិច្ច



Scanned with CamScanner

ចិញ្ចឹមកូន ក្នុងមួយខែ២០០$ គិតចាប់ពីថ្ងៃចេញសាលក្រម ឲ្យទៅដើមចោទឈ្មោះ [redacted] ថារ៉ូ យោងតាមមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី។

៥.គូភាគីអះអាងថាទ្រព្យសម្បត្តិរួមមាន៖ ដី និងផ្ទះលំនៅឋាន មានទីតាំងស្ថិតនៅភូមិ១ សង្កាត់លេខ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ១៨០១០៤០៥-៣៨៩០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦ និងរថយន្តម៉ាកLEXUS RX300 ពណ៌ស ស្លាកលេខ ភ្នំពេញ 2Z-០៣២២ គូភាគីបានព្រមព្រៀងគ្នាសុំលក់បែងចែកចំណែកជាពីរស្មើគ្នា ដូច្នេះតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគីតាមមាត្រា៩៨០ នៃក្រមរដ្ឋប្បវេណី។

៦.ដើមចោទឈ្មោះ [redacted] ថារ៉ូ ត្រូវទទួលបន្ទុកប្រាក់ប្រដាប់ក្ដី យោងតាមបញ្ញត្តិមាត្រា ៦៤នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## **ហេតុដូច្នេះសម្រេច**

១/ឲ្យដើមចោទឈ្មោះ [redacted] ថារ៉ូ និងចុងចម្លើយឈ្មោះ [redacted] ណារីរ័ត្ន លែងលះពីគ្នាតាមការព្រមព្រៀងរបស់គូភាគី យោងតាមមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី។

២/ប្រគល់កូនឈ្មោះ [redacted] សុមុនី ភេទប្រុស កើតនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៨ ឲ្យទៅដើមចោទឈ្មោះ [redacted] ថារ៉ូ គ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សា យោងតាមមាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី។

៣/ភាគីដែលពុំមានអំណាចមេបា មានសិទ្ធិទៅសួរសុខទុក្ខកូន។ រីឯភាគីដែលទទួលសិទ្ធិថែរក្សាកូន ត្រូវបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងដល់ភាគីម្ខាងទៀត។ តែតម្រូវឲ្យចុងចម្លើយឈ្មោះ [redacted] ណារីរ័ត្ន ផ្ដល់អាហារកិច្ចចិញ្ចឹមកូន ក្នុងមួយខែ២០០$ គិតចាប់ពីថ្ងៃចេញសាលក្រម ឲ្យទៅដើមចោទឈ្មោះ [redacted] ថារ៉ូ យោងតាមមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី។

៤/បែងចែកទ្រព្យរួមតាមការព្រមព្រៀងរបស់គូភាគី តាមមាត្រា៩៨០ នៃក្រមរដ្ឋប្បវេណី ដូចខាងក្រោម៖

-ដី និងផ្ទះលំនៅឋាន មានទីតាំងស្ថិតនៅភូមិ១ សង្កាត់លេខ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ១៨០១០៤០៥-៣៨៩០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦ ត្រូវលក់យកប្រាក់បែងចែកឲ្យដើមចោទឈ្មោះ [redacted] ថារ៉ូ ពាក់កណ្ដាល និងចុងចម្លើយឈ្មោះ [redacted] ណារីរ័ត្ន ពាក់កណ្ដាល។

-រថយន្តម៉ាកLEXUS RX300 ពណ៌ស ស្លាកលេខ ភ្នំពេញ 2Z-០៣២២ ត្រូវលក់យកប្រាក់បែងចែកឲ្យដើមចោទឈ្មោះ [redacted] ថារ៉ូ ពាក់កណ្ដាល និងចុងចម្លើយឈ្មោះ [redacted] ណារីរ័ត្ន ពាក់កណ្ដាល។

៥/ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ យោងតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

សាលក្រមនេះប្រកាសជាសាធារណៈ នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៩ រក្សាសិទ្ធិប្ដឹងឧទ្ធរណ៍រយៈពេល១ (មួយ) ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រម។

ថ្ងៃព្រហស្បតិ៍ ៥កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ខេត្តព្រះសីហនុ, ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៩

**ចៅក្រម**

**ហត្ថលេខា និងត្រា** [redacted]

---

**បានឃើញ**

**ចៅក្រម**

[redacted]

**បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម**

**ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៩**

**ក្រឡាបញ្ជី**

[redacted]

Scanned with CamScanner